RÉPUBLIQUE FRANÇAISE

*Liberté*
*Égalité*
*Fraternité*

INSTITUT FRANÇAIS

*Liberté*
*Créativité*
*Diversité*




BRED BANK · CAMBODIA AIRPORTS · OCIC · le Bistrot · PPP · STUDIO IMAGES · WHITE MANSION

« តាមទាន់ »

វិទ្យាស្ថានបារាំងកម្ពុជា



## *មាតិកា*

រដូវកាលវប្បធម៌ "តាមទាន់"

មហោស្រពរូបថតភ្នំពេញឆ្នាំ២០២៤

ម៉ក់ រ៉េមីស្សា

សម្លេងរូបថត

*អួង សំអាង*

*កំពង់សោមដាទីស្រលាញ់ (The Beloved Kampong som)*

15 x 4

ផ្ទះរូបថត - ស្ទូឌីយោអ៊ីមេចស៍

© ម៉ក់ រ៉េមីស្សា, *Water is Life*, ២០០៩

## *រដូវកាលវប្បធម៌ "តាមទាន់" ចាប់ពីថ្ងៃទី ២៦ ខែកញ្ញាដល់ថ្ងៃទី ១៥ ខែមករា*

វិទ្យាស្ថានបារាំងកម្ពុជា មានសេចក្ដីសោមនស្សរីករាយសូមគោរពអញ្ជើញលោកអ្នក ឱ្យមកទស្សនាស្វែងយល់ពីរដូវកាលវប្បធម៌ថ្មីរបស់ខ្លួន ដែលមានចំណងជើងថា "តាមទាន់" ដែលនឹងរៀបចំឡើងចាប់ពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៥។ រដូវកាលវប្បធម៌នេះ នឹងបង្ហាញពីសិល្បៈនៃការថតរូប ដែលរូបភាពនីមួយៗ រៀបរាប់ប្រាប់ពីរឿងរ៉ាវមួយ ដោយចាប់យកខណៈពេលវេលាដ៏ខ្លីនានា និងបង្ហាញពីអារម្មណ៍ដ៏ជ្រាលជ្រៅជាច្រើន។

រដូវកាលវប្បធម៌ថ្មីនេះ នឹងទទួលស្វាគមព្រឹត្តិការណ៍សំខាន់ៗចំនួនពីរ៖ ចាប់ពីថ្ងៃទី ២៦ ខែកញ្ញា ដល់ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០២៤ ការទស្សនាមើលថយខាងក្រោយរំលឹកឡើងវិញមួយ នៃស្នាដៃរបស់អ្នករូបថតលោកម៉ក់ រ៉េមីស្សា នឹងត្រូវបានតាំងបង្ហាញនៅក្នុងវិចិត្រសាលវិទ្យាស្ថានបារាំងកម្ពុជា ហើយបន្តដោយការតាំងពិព័រណ៍មួយទៀត ចាប់ពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៥ សម្រាប់ខួប១៥ឆ្នាំនៃមហោស្រពរូបថតភ្នំពេញ។

តាមរយៈការបង្កើតថ្មែប្រឌិតបែបប្លាស្ទិក និងរូបថតរបស់គាត់ លោកម៉ក់ រ៉េមីស្សា បង្ហាញពីទស្សនៈរបស់គាត់ចំពោះបញ្ហាបរិស្ថាន និងបង្ហាញពីតុល្យភាពដ៏ផុយស្រួយនៃធាតុនានារបស់ធម្មជាតិ និងសង្គម។ គាត់ ក៏ធ្វើការលើការចងចាំនៃសោកនាដកម្មប្រល័យពូជសាសន៍ ដែលបង្កដោយខ្មែរក្រហមផងដែរ។

នៅក្នុងក្របខណ្ឌនៃមហោស្រពរូបថតភ្នំពេញ វិចិត្រសាលរបស់វិទ្យាស្ថានបារាំងកម្ពុជា បន្ទាប់ពីការតាំងពិព័រណ៍របស់លោកម៉ក់ រ៉េមីស្សា នឹងទទួលជម្រើសរូបថតមួយ ដែលរំលឹកពីខួបដប់ប្រាំឆ្នាំនៃមហោស្រពរូបថតភ្នំពេញ។ ការតាំងពិព័រណ៍នេះ មានគោលបំណងជំរុញការផ្លាស់ប្ដូររវាងសិល្បករអ៊ឺរ៉ុប និងអាស៊ី។ អ្នកថតរូបចំនួន ៦០ នាក់ដែលធ្លាប់បានដាក់តាំងបង្ហាញស្នាដៃរួចហើយ នៅក្នុងមហោស្រពនេះ ត្រូវបានស្នើសុំឱ្យផ្ញើរូបថតថ្មីមួយមិនធ្លាប់មានពីមុន ឬមិនធ្លាប់ដាក់តាំងពិព័រណ៍នៅក្នុងប្រទេសកម្ពុជាពីមុនមក។ សិល្បករទាំងនេះភាគច្រើនមកពីអ៊ឺរ៉ុប និងអា

ស៊ី។ ទិដ្ឋភាពមើលថយក្រោយរំលឹកឡើងវិញនេះ នឹងផ្តល់ជូននូវទេសភាពពេញលេញនៃការវិវត្តវិស័យថតរូប និងឥទ្ធិពលរបស់វានៅក្នុងប្រទេសកម្ពុជា។

នៅលើជញ្ជាំងនៃបណ្ណាល័យពហុឯកសាររបស់វិទ្យាស្ថានបារាំងកម្ពុជា ស្នាដៃរបស់លោក អួង សំអាង នឹងត្រូវដាក់បង្ហាញជូនទស្សនា។ គាត់ថតចាប់យកភាពស្រស់ស្អាត និងភាពស្មុគ្រស្មាញនៃពិភពលោក ដោយធ្វើឱ្យការថតរូបទេសភាពតាមវាលស្រែ ជាវិស័យដែលគាត់ជ្រើសរើស។ តំណាងឱ្យវិស័យថតរូបដ៏វ័យក្មេងកម្ពុជា អ្នកថតរូបនេះ បង្ហាញជូននូវទិដ្ឋភាពមួយថ្មីប្លែកមិនដែលមាន និងប្រកបដោយភាពច្នៃប្រឌិតលើសម្បត្តិនៃបេតិកភណ្ឌធម្មជាតិរបស់ប្រទេសនេះ។

“តាមទាន់” គឺជាឱកាសដ៏ល្អក្នុងការទស្សនាស្វែងយល់ និងគយគន់សិល្បៈនៃការថតរូបនៅគ្រប់ទម្រង់របស់វាទាំងអស់។ តាមរយៈការតាំងពិពណ៌ទាំងនេះ យើងសូមគោរពអញ្ជើញលោកអ្នក ឱ្យស្វែងយល់ពីភាពសម្បូរបែបនៃចំណេះដឹងផ្នែកថតរូប។

ទោះជាដើម្បីធ្វើឱ្យអមតៈនូវរូបភាពដ៏ស្និទ្ធស្នាលមួយ រុករកទេសភាពដ៏អស្ចារ្យ ឬកត់ត្រាខណៈពេលវេលាពិតៗ ការថតរូបបង្ហាញពីភាពស្រស់ស្អាត និងភាពស្មុគស្មាញនៃពិភពលោកដែលនៅជុំវិញយើង។ រូបថតទាំងនេះ អាចឱ្យស្វែងយល់ពីលទ្ធភាពច្នៃប្រឌិតរាប់មិនអស់ ដោយផ្តល់នូវវេទិកាមួយដ៏មានថាមវន្តមួយ សម្រាប់ការបញ្ចេញមតិផ្ទាល់ខ្លួន ឬជាសមូហភាព។

ពួកយើងកំពុងរង់ចាំស្វាគមលោកអ្នក ឱ្យអញ្ជើញមកចូលរួមឱ្យបានច្រើនកុះករ ដើម្បីអបអរសាទរជាមួយគ្នា នូវការច្នៃប្រឌិត និងការបញ្ចេញមតិបែបមើលឃើញនៅវិទ្យាស្ថានបារាំងកម្ពុជា និងនៅគ្រប់ទីកន្លែងផ្សេងទៀតនៃមហោស្រព។

## *មហោស្រពរូបថតភ្នំពេញឆ្នាំ ២០២៤*

មហោស្រពរូបថតភ្នំពេញ បានក្លាយយ៉ាងឆាប់រហ័ស ជាព្រឹត្តិការណ៍អន្តរជាតិដ៏សំខាន់មួយសម្រាប់អ្នកថតរូប និងអ្នកចូលចិត្តថតរូបនៅអាស៊ីអាគ្នេយ៍។ ត្រូវបានបង្កើតឡើងកាលពី ១៥ ឆ្នាំមុន មហោស្រពនេះបានក្លាយជាវេទិកាជួបជុំដ៏សំខាន់មួយ សម្រាប់សិល្បករមកពីអាស៊ី អឺរ៉ុប និងកម្ពុជា ដែលចង់ចែករំលែកចំណាង់ចំណូលចិត្តរបស់ពួកគេ។ ដូច្នេះ មហោស្រពនេះជំរុញការផ្លាស់ប្តូរ និងការសហការគ្នារវាងអ្នកថតរូបម្នាក់ៗ ដែលមកពីមជ្ឈដ្ឋានផ្សេងៗគ្នា។

មហោស្រពរូបថតភ្នំពេញ មានគោលបំណងលើកកម្ពស់ការផ្លាស់ប្តូរ លើកទឹកចិត្តដល់ការថែរក្សាអតិរក្សវប្បធម៌ និងបរិស្ថាន ដោយបណ្តុះនូវចម្រុះភាពមួយប្រកបដោយភាពច្នៃប្រឌិតដ៏សម្បូរបែប។ គោលបំណងរបស់មហោស្រពនេះ គឺដើម្បីលើកកម្ពស់ការលេចចេញនូវអ្នកមានទេពកោសល្យវ័យក្មេងផ្នែកថតរូបរបស់កម្ពុជា។

ឆ្នាំនេះ មហោស្រពបានសម្ភោធសាលា “ស្ទូឌីយោអ៊ីមេចស៍ ផ្ទះរូបថត”។ មហោស្រពរូបថតថ្មីនេះ សូមគោរពអញ្ជើញលោកអ្នកឱ្យទស្សនាស្វែងយល់ពីប្រទេសកម្ពុជា ក្រោមទស្សនៈថ្មីមួយ។ សូមចាប់ផ្តើមដំណើរផ្សេងព្រេងនៅទូទាំងផ្ទៃប្រទេស ដោយតាមដានដំណើរថតរូបដែលនឹងណែនាំលោកអ្នកឱ្យស្គាល់ពីទេសភាព និងខណៈពេលវេលាទាំងនេះដែលចាប់ថតដោយសិល្បករ។ សូមចាប់ផ្តើមដំណើរកម្សាន្តរបស់លោកអ្នកនៅក្នុងទីក្រុងភ្នំពេញ ដែលវិទ្យាស្ថានបារាំងកម្ពុជា សូមអញ្ជើញលោកអ្នក ឱ្យជ្រមុជខ្លួនចូលទៅទស្សនាស្វែងយល់ពីស្នាដៃរបស់លោក អ្នង សំអាង និងទស្សនាការមើលថយក្រោយរំលឹកឡើងវិញលើអ្នកថតរូបចំនួន ៦០ នាក់ ដែលបានកត់ត្រាប្រវត្តិសាស្ត្រនៃពិធីមហោស្រពនេះ។ បន្ទាប់មក បន្តដំណើរទៅស្ថានទូតបារាំង ដែលនៅទីនោះ ជញ្ជាំងរបស់ស្ថានទូតទទួលស្វាគមន៍ រូបថតដ៏គួរឱ្យចាប់អារម្មណ៍របស់លោក Vincent Fournier។ ហ្វេសតូរី ភ្នំពេញ នឹងបើកទ្វាររបស់ខ្លួន ដើម្បីអញ្ជើញលោកអ្នកឱ្យទស្សនាស្វែងយល់អំពីទេពកោសល្យសិល្បៈរបស់លោក Alexandre Bergamini អ្នកធ្វើនិវាសដ្ឋាននៃកម្មវិធី Villa Marguerite Duras ដែលរួមបញ្ចូលគ្នានូវការថតរូប និងសំណេរ។

© បណ្ណសារ វិទ្យាស្ថានបារាំងកម្ពុជា។



## *លោក ម៉ក់ រ៉េមីស្សា*

លោក ម៉ក់ រ៉េមីស្សា គឺជាអ្នកថតរូបជនជាតិខ្មែរម្នាក់ កើតនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧០ ដែលត្រូវបានទទួលស្គាល់ថាជាអ្នកថតរូបម្នាក់ក្នុងចំណោមអ្នកថតរូបដ៏អស្ចារ្យជាងគេក្នុងជំនាន់របស់គាត់។ ជាអ្នកតំណាងនៃការរស់ឡើងវិញនៃវិស័យថតរូបនិងរូបភាព ក្រោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ការមើលឃើញរបស់គាត់គឺចាំបាច់៖ គាត់ធ្វើជាសាក្សី តាមរយៈរូបថតរបស់គាត់ ដោយផ្សះផ្សាមនុស្សជាមួយនឹងពិភពលោក និងការចងចាំនានា។ ភាពធន់ និងការបង្កើតច្នៃប្រឌិតរួមបញ្ចូលគ្នា ឆ្ពោះទៅរកការថតរូបដែលមានលក្ខណៈមនុស្សជាតិ ជាការថតរូបមួយដែលមានការប្ដេជ្ញាចិត្ត។

© FP Mag, ម៉ក់ រ៉េមីស្សា/Asia Motion



ដោយស្រលាញ់ចូលចិត្តខ្លាំងចំពោះការគូររូប គាត់បានចូលរៀននៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងឆ្នាំ១៩៨៥ ជាកន្លែងដែលគាត់ត្រូវបានកត់សម្គាល់ ដោយទេពកោសល្យ និងការប្តេជ្ញាចិត្តរបស់គាត់។ ការជួបរបស់គាត់ជាមួយលោក Thierry Diwo អ្នកថតរូបប្រាសាទអង្គរ បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស (១៩៩១) បានផ្តួចផ្តើមគាត់ចូលក្នុងសិល្បៈនៃការថតរូប។ បញ្ចប់ការសិក្សានៅឆ្នាំ១៩៩៥ លោកម៉ក់ រ៉េមី ស្សា បានងាកទៅរកវិស័យថតរូបបែបកាសែត ជាកន្លែងដែលគាត់ត្រូវបានគេស្គាល់យ៉ាងឆាប់រហ័ស។ គាត់បានចាប់ផ្តើមអាជីពរបស់គាត់ដោយសហការជាមួយប្រព័ន្ធផ្សព្វផ្សាយល្បីៗជាច្រើន ដូចជាទីភ្នាក់ងារសារព័ត៌មានអឺរ៉ុប (EPA) កាសែតCambodge Soir ក៏ដូចជាអង្គការអន្តរជាតិជាច្រើនដូចជា UNESCO និង UNICEF ។

នៅឆ្នាំ ១៩៩៧ គាត់បានឈ្នះរង្វាន់ទី ១ និងទី ៣ ក្នុងការប្រកួតប្រជែងរូបថតកាសែតថ្នាក់ជាតិ ដែលរៀបចំដោយក្លឹបអ្នកឆ្លើយឆ្លងព័ត៌មានបរទេស។

ទន្ទឹមនឹងការងារជាអ្នកថតរូបកាសែត លោកម៉ក់ រ៉េមីស្សា បានបង្កើតគម្រោងសិល្បៈពិសេសមួយ ដែលរួមបញ្ចូលការគូររូប និងការថតរូប។ វិធីសាស្រ្តប្រកបដោយភាពច្នៃប្រឌិតរបស់គាត់ ដែលបង្ហាញពីបញ្ហាប្រឈមរបស់បរិស្ថាន តាមរយៈស្នាដៃប្លាស្ទិក បានទទួលការទទួលស្គាល់ជាអន្តរជាតិ។ គាត់ក៏ចាប់អារម្មណ៍នឹងការចងចាំនៃអំពើប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហមផងដែរ។

ពេញមួយអាជីពរបស់គាត់ គាត់បានពង្រីកការងារថតរូបរបស់គាត់ដោយសហការជា និងវិទ្យាស្ថានបារាំងកម្ពុជា។ លោកក៏បានក្លាយជាសិល្បករខ្មែរដំបូងគេ ដែលបង្រៀនការថតរូបនៅស្ទូឌីយោ អ៊ីមេចស៍។

ស្នាដៃរបស់គាត់ត្រូវបានដាក់តាំងបង្ហាញនៅក្នុងស្ថាប័ន និងមហោស្រពដ៏មានកិត្យានុភាពជាច្រើន រួមទាំងសារមន្ទីរ Musée du quai Branly នៅទីក្រុងប៉ារីស សារមន្ទីរវិចិត្រសិល្បៈនៃប្រទេសកាណាដា នៅទីក្រុង Ottawa សារមន្ទីរសិល្បៈសិង្ហបុរី មហោស្រពរូបថតភ្នំពេញ ជំនួបនានានៃទីក្រុង Arles និង Lille ៣០០០ ។ រូបថតរបស់គាត់ ក៏ជាផ្នែកមួយនៃប

ណ្តុំស្នាដៃសាធារណៈ និងឯកជន ដ៏ល្បីល្បាញលើពិភពលោក ដូចជា សារមន្ទីរ Guimet នៅទីក្រុងប៉ារីស សារមន្ទីរជាតិ Victoria ក្នុងទីក្រុង Melbourne និងសារមន្ទីរ Musée Photo Elysée ក្នុងទីក្រុង Lausanne ជាដើម។

នៅឆ្នាំ២០២១ លោកម៉ក់ រ៉េមីស្សា ត្រូវបានជ្រើសរើស ក្នុងចំណោមបេក្ខជនចុងក្រោយចំនួន ១២ នាក់ សម្រាប់ពានរង្វាន់ Prix Pictet ដែលជារង្វាន់ដ៏មានកិត្យានុភាព ដែលឧទ្ទិសដល់ការថតរូបសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពព។







© ម៉ក់ រ៉េមីស្សា, *ត្រី និងស្រមោច*, ២០០៥
*ព្រៃដែលឆាបឆេះដោយអណ្ដាតភ្លើង* ឆ្នាំ ២០១២
*ពីការបរបាញ់ ដល់ការបាញ់ប្រហារ*ឆ្នាំ ២០១៨

## *សម្លេងរូបថត*

### ***Water is life*** (*ទឹកគឺជាជីវិត*)

*Water is Life* ជាកម្រងរូបភាព ដែលបានផលិតឡើងក្នុងឆ្នាំ២០០៩ បង្ហាញពីសារៈសំខាន់នៃទឹកសម្រាប់គ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតនៅលើផែនដី រួមទាំងពពួកសត្វ រុក្ខជាតិ និងមនុស្ស។

តាមរយៈរូបភាពជាច្រើនសន្លឹកនេះ លោកម៉ាក់ រ៉េមីស្ស៊ា បង្ហាញថា ទឹកគឺជាប្រភពនៃទម្រង់ជាច្រើននៃជីវិត។

គាត់លើកឡើងពីបញ្ហាបរិស្ថានដោយក្ដីបារម្ភយ៉ាងជ្រាលជ្រៅ។ លោកសង្ឃឹមថា ស្នាដៃរបស់លោក នឹងជំរុញឱ្យសាធារណជនទាំងអស់គិតពិចារណាឡើងវិញ អំពីសារៈសំខាន់នៃការថែរក្សាទឹក ដែលជាធនធានដ៏សំខាន់ចាំបាច់សម្រាប់ជីវិត និងសុខភាពនៃភពផែនដីរបស់យើង។

កម្រងរូបថតនេះ រួមមានរូបថតនានាដែលថតចាប់ពពួកសត្វទាំងឡាយក្នុងទឹក។ យើងអាចសង្កេតមើលឃើញ ត្រីជាច្រើនប្រភេទ បបែល ខ្ចៅខ្យង កង្កែប និងសូម្បីតែអណ្ដើក។ សត្វទាំងនេះនីមួយៗ បញ្ចេញសារធាតុចម្រុះពណ៌និងរំអិល ដែលលាយជាមួយនឹងទឹកថ្លា ដែលពួកវាបណ្ដែតខ្លួនឡើង។ យើងក៏សង្កេតឃើញផងដែរ នៅក្នុងកម្រងរូបថតនេះ រូបភាពដែលបង្ហាញពីមនុស្សលោក ដែលហាក់ដូចជាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទឹក។ តាមរបៀបនេះ លោកម៉ាក់ រ៉េមីស្ស៊ា បង្កើតពិភពលោកមួយដែលសត្វទាំងនេះវិវត្តនៅក្នុងទឹកភ្លឺថ្លាអាចមើលឃើញ និងបង្វិលខ្លួន។

© ម៉ាក់ រ៉េមីស្ស៊ា, *Water is Life*, ២០០៩



ទោះបីជាគួរឱ្យចាប់អារម្មណ៍ក៏ដោយ រូបភាពទាំងនេះបង្ហាញពីទិដ្ឋភាពដ៏ខ្មៅងងឹតមួយ៖ សត្វសមុទ្រហាក់បីដូចជាជាប់ឃាំងនៅក្នុងកន្លែងដែលមើលទៅគួរឱ្យទាក់ទាញនេះ។ អារម្មណ៏នៃការស្លាប់ កើតឡើងបន្តិចម្តងៗ ដែលធ្វើឱ្យកន្លែងបំភាន់ផ្លូវចិត្តនេះ ក្លាយជាសារធាតុពុលមួយ។ ដូច្នេះហើយ លោកម៉ក់ រ៉េមីស្សា អាចសម្រេចបានយ៉ាងប៉ិនប្រសប់ ក្នុងការបង្កើតនៅក្នុងកម្រងរូបភាពនេះ នូវភាពផ្ទុយគ្នា រវាងភាពស្រស់ស្អាតជាក់ស្តែងខាងក្រៅនៃស្នាដៃ និងភាពមិនសុខស្រួលបង្កប់ ដែលបង្ហាញពីការយល់ដឹងអំពីបរិស្ថាន។

សម្រាប់ការផលិតកម្រងរូបភាពនេះ មិនមានសត្វណាមួយត្រូវបានសម្លាប់នោះទេ។ សត្វទាំងនេះបានស្លាប់រួចទៅហើយ នៅពេលដែលពួកគេត្រូវបានទិញមក។

© ម៉ក់ រ៉េមីស្សា, *Water is Life*, ២០០៩



## ***Flamed forest*** ( *ភ្លើងឆេះព្រៃ*)

កម្រងរូបថតនេះ ត្រូវបានផលិតឡើងក្នុងឆ្នាំ២០១២។

លោកម៉ក់ រ៉េមីស្សា បង្ហាញពីរបៀប ដែលព្រៃឈើដែលមានសារៈសំខាន់ចំពោះជីវចម្រុះ ត្រូវបានឆាបឆេះត្របាក់ដោយអណ្តាតភ្លើង។ ភ្លើងនិងកម្ទេចផេះ លេចចេញជាទម្រង់ពិសេស ដែលបង្ហាញវត្តមានរបស់សត្វមានជីវិត។ កម្រងរូបថត *Flamed Forest* គឺជាការព្រមានមួយ៖ វាបង្ហាញពីទំនាក់ទំនងបែបបំផ្លិចបំផ្លាញ ដែលមនុស្សជាតិអាចមានជាមួយបរិស្ថាន។ ដូចនេះ លោក ម៉ក់ រ៉េមីស្សា បង្កើតទាំងការគោរពចំពោះធម្មជាតិ និងការដាស់តឿនមួយ។

© ម៉ក់ រ៉េមីស្សា, *Flamed forest*, ២០១២



## *Left 3 Days (ចាកចេញ៣ថ្ងៃ)*

នៅក្នុងកម្រងរូបថតរបស់គាត់ *Left 3 Days* ដែលបានផលិតឡើងក្នុងឆ្នាំ ២០១៤ លោកម៉ក់ រ៉េមីស្សា ដកស្រង់យកគំនិតពីល្ខោនស្រមោលបុរាណ ដើម្បីបង្ហាញពីការចងចាំរបស់គាត់ អំពីការជម្លៀសចេញពីទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧៥។ នៅពេលដំបូងនៃការជម្លៀសមនុស្សចេញនេះ ខ្មែរក្រហមធ្វើឱ្យទីក្រុងទទេស្អាតមិនមានមនុស្ស ហើយប្រាប់ប្រជាជនថាពួកគេនឹងចាកចេញត្រឹមតែ "បីថ្ងៃ" ប៉ុណ្ណោះ ។ កាលនោះ លោកម៉ក់ រ៉េមីស្សា មានអាយុ ៥ ឆ្នាំ លោកបានឆ្លងកាត់ការជម្លៀសចេញដ៏ឃោរឃៅនេះ ដែលបានប្រែក្លាយរាជធានី ទៅជាទីក្រុងស្ងាត់ជ្រងំដូចខ្មោច ដោយបន្សល់ទុកតែដានស្នាមនានា នៃជីវិតមួយដែលត្រូវបានលុបចោល៖

« ទាហានស្លៀកពាក់ខ្មៅ - ភាគច្រើននៅវ័យក្មេង - បានបញ្ជាឱ្យប្រជាជនទាំងអស់ចាកចេញពីផ្ទះរបស់ពួកគេ ត្រឹមតែបីថ្ងៃប៉ុណ្ណោះ សូម្បីតែអ្នកជំងឺ ក៏ត្រូវតែចាកចេញពីមន្ទីរពេទ្យក្នុងទីក្រុងដោយគ្មានព័ត៌មានច្បាស់លាស់។ គ្រួសាររបស់ខ្ញុំបានលាក់ខ្លួននៅផ្ទះរបស់យើងមួយយប់ ដោយសង្ឃឹមថាស្ថានការណ៍នឹងប្រសើរឡើង។ ផ្ទុយទៅវិញ ដោយយើងខកចិត្តយ៉ាងខ្លាំង រាជធានីដែលធ្លាប់មានសភាពអ៊ូអរ និងពោរពេញដោយជីវិត បានក្លាយជាទីក្រុងខ្មោចស្ងាត់ជ្រងំ។ »

ម៉ក់ រ៉េមីស្សា, "Fotografiska New York: ៣នរង្វាន់ Prix Pictet Fire: ម៉ក់ រ៉េមីស្សា", *The Eye of Photography*, ២០២៣

សម្រាប់កម្រងរូបថតនេះ លោកម៉ក់ រ៉េមីស្សា បង្កើតឡើងវិញនូវឈុតឆាកដែលជាប់ក្នុងអារម្មណ៍របស់គាត់ ដោយប្រើប្រាស់ក្រដាសកាត់រូបដែលគាត់ធ្វើឱ្យមានចលនា ដោយសារការលេងពន្លឺ និងស្រមោល។ វិធីសាស្ត្រសិល្បៈនេះ រួមចំណែកដល់ការអភិវឌ្ឍការចងចាំដ៏ឈឺចាប់នៃអតីតកាល ដោយហេតុនេះហើយ អាចឱ្យមនុស្សជំនាន់ក្រោយយល់ដឹងពីប្រវត្តិសាស្ត្រ និងស្លាកស្នាមនានានៃប្រទេសរបស់ពួកគេ។ ដូច្នេះហើយ ក្នុងចំណោមរូបថតទាំងនេះ យើងសង្កេតឃើញស្រមោលរូបភាពរបស់ខ្មែរក្រហមប្រដាប់អាវុធ គ្រួសារទាំងឡាយដែលត្រូវបានជម្លៀសចេញដោយបង្ខំ ម្ដាយមីងរបស់គាត់ដែលបង្ខំចិត្តត្រូវស្ពាយកូនប្រុសដែលឈឺរបស់គាត់ ដើម្បីយកគេចេញពីមន្ទីរពេទ្យ ឬសូម្បីតែសាកសពជាច្រើននៅ

តាមដងផ្លូវ។ ស្រមោលរូបទាំងនេះ ជួយជម្នះភាពស្ងប់ស្ងាត់ និងការឈឺចាប់ដែលតែងតែហ៊ុំព័ទ្ធរយៈពេលសោកនាដកម្មនេះ។

សិល្បៈរបស់លោក ម៉ក់ រ៉េមីស្សា មិនត្រឹមតែជាសក្ខីភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការឧទ្ទិសដល់ក្រុមគ្រួសារ ឪពុក ជីតា និងពូទាំងបីរបស់គាត់ ព្រមទាំងជនរងគ្រោះទាំងអស់នៃពេលវេលាដ៏សោកនាដកម្មនេះផងដែរ។

ស៊េរីនេះគឺជាផ្នែកមួយនៃការដាក់តាំងអចិន្ត្រៃយ៍នៅសារមន្ទីរជាតិ Victoria (អូស្ត្រាលី) សារមន្ទីរ Musée Photo Elysée (ស្វីស) សារមន្ទីរ Guimet (បារាំង)។





© ម៉ក់ រ៉េមីស្សា, *Left 3 Days*

## **Fish and Ants (*ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី*)**

«ទឹកឡើង ត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី។»
សុភាសិតខ្មែរ, « Getxo Photo 2014 », *The Eye of Photography*, ២០១៤

សម្រាប់លោក ម៉ក់ រ៉េមីស្សា សុភាសិតនេះ ចាប់យកការពិតបច្ចុប្បន្ន និងភាពខុសគ្នានានាដែលមាននៅក្នុងប្រទេសកម្ពុជាបានយ៉ាងល្អ។ ស្ថានភាពរបស់មនុស្សគ្រប់រូប ត្រូវបានកំណត់ដោយកត្តានានា ដូចជាលទ្ធភាពទទួលបានទឹក។ វត្តមាន ឬអវត្តមានរបស់ទឹក អាចមានផលប៉ះពាល់ដោយផ្ទាល់ទៅលើទិដ្ឋភាពនានានៃជីវិតប្រចាំថ្ងៃរបស់យើង ដូចជាការងារ នយោបាយ ការអប់រំ សុខភាព និងសូម្បីតែអាហារ។

ដើម្បីផ្តល់ជាជីវិតដល់ទស្សនៈនេះ លោក ម៉ក់ រ៉េមីស្សា បានបង្កើតជាកម្រងរូបថតក្នុងឆ្នាំ២០០៥ ដែលមានឈ្មោះថា *Fish and Ants*។ កម្រងរូបថតនេះ ត្រូវបានកត់សម្គាល់ដោយពណ៌ភ្លឺរក់រវើករបស់វា ដែលផ្តល់ឱ្យស្នាដៃទាំងនេះ នូវថាមវន្តពិតប្រាកដមួយ។

ដើម្បីផលិតថតរូបទាំងនេះ គាត់បានដាក់ត្រីងាប់មួយ នៅលើដី ក្បែរភូមិកំណើតនាពេលកុមារភាពរបស់គាត់។ បន្ទាប់មក គាត់បានរក្សាភាពអត់ធ្មត់អស់ជាច្រើនម៉ោង ដើម្បីសង្កេតមើលការមកដល់របស់ស្រមោច។ ដោយសារការមកដល់នៃធម្មជាតិនេះ គាត់អាចចាប់យកខណៈពេលដែលសត្វល្អិតតូចនេះ ចាប់ផ្តើមពាំសាកសពត្រី និងដឹកជញ្ជូនសាកសពនេះ។

សត្វទាំងនេះ ពិតជាតំណាងឱ្យសកម្មភាពនានា និងជីវិតប្រចាំថ្ងៃរបស់មនុស្សលោក។ ពួកគេ គឺជាពាក្យប្រៀបធៀបបែបសង្គមមួយ ដែលសារចម្បងសង្កត់ធ្ងន់លើទំនាក់ទំនងរបស់មនុស្ស ការងាររបស់ពួកគេ និងសាមគ្គីភាពរបស់ពួកគេ នៅពេលប្រឈមមុខនឹងការលំបាកនានា។ ការបង្កើតបែបច្នៃប្រឌិតរបស់លោក ម៉ក រ៉េមីស្សា មានគុណសម្បត្តិបែបកំណាព្យកាបឃ្លោងពិតប្រាកដមួយ។

© ម៉ក់ រ៉េមីស្សា, *Fish and Ants*, ២០០៥



## ***From Hunting to Shooting*** (ចាកចេញពីការប្រមាញ់ទៅជាការថតរូប)

សម្រាប់កម្រងរូបថតនេះ ដែលមានឈ្មោះថា *From Hunting to Shooting* លោកម៉ក់ រ៉េមីស្សាបានយកគំនិតបំផុសពីល្ខោនស្រមោលមួយ។ គាត់បានផលិតកម្រងរូបថតនេះឡើង ក្នុងឆ្នាំ២០១៨។

តាមរយៈរូបភាពទាំងនេះ លោកម៉ក់ រ៉េមីស្សា សង្ឃឹមថានឹងលើកកម្ពស់ការយល់ដឹងរបស់មនុស្សគ្រប់គ្នា អំពីផលប៉ះពាល់អវិជ្ជមាននៃការបរបាញ់សត្វស្លាប ដើម្បីឱ្យពួកគេផ្លាស់ប្តូរទម្លាប់របស់ពួកគេ។

ក្នុងពេលកុមារភាព លោកម៉ក់ រ៉េមីស្សា បានយល់ឃើញថា ការបរបាញ់សត្វស្លាបជាល្បែងមួយ ហើយមិនបានវាស់វែងពីផលប៉ះពាល់នៃសកម្មភាពទាំងនេះទេ។ ជាមួយពេលវេលា គាត់បានយល់ដឹងពីសារៈសំខាន់ដ៏ចាំបាច់ក្នុងការការពារប្រភេទសត្វទាំងនេះ។ តាមរយៈកម្រងរូបភាពទាំងនេះ គាត់ព្យាយាមបញ្ជ្រាបការយល់ដឹង និងលើកកម្ពស់ការផ្លាស់ប្តូរក្នុងអាកប្បកិរិយារបស់យើង ជាពិសេសទាក់ទងនឹងការបរបាញ់សត្វស្លាបព្រៃ សម្រាប់ពាណិជ្ជកម្ម ឬការបរិភោគ។

ដូច្នេះហើយ កម្រងរូបថតនានា ដែលផលិតដោយ លោកម៉ក់ រ៉េមីស្សា ដូចជា *From Hunting to Shooting* លើកឡើងពីបញ្ហាបរិស្ថាន និងសង្គម តាមរយៈរូបថតដែលផ្តុំឡើងយ៉ាងល្អិតល្អន់ ត្រូវបានរចនាច្នៃប្រឌិតឡើងដើម្បីលើកទឹកចិត្តជុំរុញដល់ការគិតពិចារណាឆ្លុះបញ្ចាំង និងការជ្រួលជ្រាបយល់ដឹង។



© ម៉ក់ រ៉េមីស្សា, *From Hunting to Shooting*, ២០១៨



## *អួង សំអាង*

កើតនៅខេត្តកំពត នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៦ លោកអួង សំអាង តំណាងឲ្យយុវជនឆាករូបថតវ័យក្មេងនៃវិស័យថតរូបនៅកម្ពុជា។ បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាក្នុងឆ្នាំ២០១៤ លោកបានបន្តការបណ្តុះបណ្តាលនៅសាលាបច្ចេកទេសដុនបូស្កូ នៅខេត្តកែប ដើម្បីសិក្សាផ្នែកប្រព័ន្ធផ្សព្វផ្សាយសង្គម និងសារព័ត៌មាន។ គឺនៅទីនោះហើយ ដែលគាត់បានរកឃើញសិល្បៈនៃការថតរូប។ នៅទីនោះ គាត់បានរៀនប្រើប្រាស់កាមេរ៉ាថតរូប និងថតចាប់យកអ្វីៗដែលនៅជុំវិញគាត់។ ក្នុងពេលហាត់រៀន គាត់បានអនុវត្តការថតរូបបែបទេសភាព ដែលបានក្លាយជាវិស័យដែលគាត់ចូលចិត្តយ៉ាងឆាប់រហ័ស។

ក្រោយបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៦ គាត់បានចូលបម្រើការងារក្នុងក្រុមផលិតខ្សែភាពយន្តរបស់ទូរទស្សន៍ប៉ុស្តិ៍លេខ ៥។ រហូតដល់ឆ្នាំ ២០១៧ គាត់បានងាកមករកការថតរូបបែបព្រឹត្តិការណ៍ នៅក្នុងក្រុមហ៊ុនឯកជនមួយ ដែលជាការចាប់ផ្តើមដំបូងនៃអាជីពរបស់គាត់នៅក្នុងពិភពនៃការថតរូប។

នៅដើមឆ្នាំ២០១៩ គាត់បានចូលរួមសិក្ខាសាលាថតរូបជាច្រើន ដែលក្នុងនោះ គាត់បានសិក្សាវគ្គមួយស្តីពីការថតរូបឯកសារ និងបែបសហសម័យនៅគម្រោងសិល្បៈស-ស។

នៅឆ្នាំ ២០២០ គាត់បានបន្តការសិក្សានៅវិទ្យាស្ថានបារាំងកម្ពុជា ជាទីកន្លែងដែលគាត់បានពង្រីកចំណេះដឹងរបស់គាត់ឱ្យកាន់តែស៊ីជម្រៅនៅស្ទូឌីយោ អ៊ីមេចស៍ ។

ចាប់ពីឆ្នាំ២០១៩ គាត់បានចូលរួមក្នុងការតាំងពិពណ៌ជាច្រើន នៅទូទាំងរាជធានីភ្នំពេញ នៅគម្រោងសិល្បៈ ស-ស នៅវិទ្យាស្ថានបារាំងកម្ពុជា និងនៅឯការដេញថ្លៃ និងការតាំងពិព័រណ៍ប្រមូលថវិកា ស-ស នៅ Factory ។



## *កំពង់សោមជាទីស្រលាញ់* (The Beloved Kampong som)

គម្រោងឯកសារបែបគុណភាពជាច្រើន ត្រូវបានបង្កើតឡើងរយៈពេលវែង។ ការត្រឡប់ទៅនឹងកន្លែងវិញ ការដើរតាមមនុស្សម្នាក់អស់រយៈពេលជាច្រើនឆ្នាំ ការលុកលុយសិក្សាស្វែងយល់ស្ថានភាពដូចគ្នា ឬបញ្ហាដូចគ្នានៅកន្លែងផ្សេងៗ អាចឱ្យយើងទៅហួសពីការសង្កេត និងរឿងរ៉ាវសាមញ្ញៗ។

នេះជាការជ្រើសរើសមួយដែលលោក អួង សំអាង បានធ្វើសម្រាប់ការអនុវត្តការថតរូប ដែលគាត់បានគិតរចនាសម្រាប់គម្រោងទាំងអស់របស់គាត់ក្នុងរយៈពេលវែង។ ជាឧទាហរណ៍ដ៏ល្អមួយត្រូវបានផ្តល់ឱ្យ ជាមួយនឹងវិធីដែលគាត់បានតាមដាន ចាប់តាំងពីឆ្នាំ២០១៩ ការវិវត្ត និងការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅនៃខេត្តព្រះសីហនុ។ គ្មានអ្វីបានកំណត់ទិសដៅ អ្នកដើមកំណើតខេត្តកំពតម្នាក់នេះទេ ក្នុងឆ្នាំ ១៩៩៦ ទៅក្នុងវិស័យថតរូប ឬទៅតំបន់ភូមិសាស្ត្រនេះទេ។ តាមពិតទៅ លោកបានហ្វឹកហាត់នៅខេត្តកែប ក្នុងផ្នែកសារព័ត៌មាន និងបណ្តាញសង្គមនៅសាលាបច្ចេកទេស ដុនបូស្កូ។ គឺនៅទីនោះហើយ ដែលគាត់បានរកឃើញការថតរូប និងរៀនពីរបៀបប្រើប្រាស់កាមេរ៉ាថតរូប។

នៅឆ្នាំ២០១៨ គាត់បានរកឃើញក្រុងព្រះសីហនុ ជារមណីយដ្ឋានមាត់សមុទ្រដែលប្រជាជនកម្ពុជាចូលចិត្ត ហើយដោយទាក់ទាញនឹងទីកន្លែងនោះ គាត់បានចាប់ផ្តើមថតរូបទេសភាពដែលបានក្លាយជាទម្លាប់ដែលគាត់ចូលចិត្ត។ នេះជាការចាប់ផ្តើមគម្រោងរបស់គាត់ *កំពង់សោមជាទីស្រលាញ់*។ នៅពេលនោះ ទីក្រុងនេះ កំពុងទទួលរងនូវការប្រែប្រួលផ្លាស់ប្តូរយ៉ាងខ្លាំង។ ក្នុងក្របខណ្ឌនៃ "ផ្លូវសូត្រ" (គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ) កំពង់ផែទឹកជ្រៅដ៏ធំបំផុតរបស់ប្រទេសនេះ ត្រូវបានបំពាក់ដោយហេដ្ឋារចនាសម្ព័ន្ធថ្មី ហើយអ្នកវិនិយោគចិនមានវត្តមានយ៉ាងច្រើន។ ក្នុងឆ្នាំ២០១៩ មានកាស៊ីណូមិនតិចជាង៦២ ទេ។ ប្រសិនបើសកម្មភាពនេះនឹងត្រូវបានរាំងស្ទះ - ខណៈពេលដែលមួយភាគបីនៃចំនួនប្រជាជនទីក្រុងឥឡូវនេះ ជាជនជាតិចិន - ដោយក្រឹត្យមួយចុះកាលពីខែសីហាឆ្នាំ២០១៩ ដែលហាមប្រាមការភ្នាល់តាមប្រព័ន្ធអ៊ីនធឺណិត (ដែលអនុញ្ញាតឱ្យមានការលាងលុយខ្មៅ) ដែលនាំឱ្យមានការចាកចេញ



របស់ជនជាតិចិនមួយចំនួន ភាពងប់ងល់នៃការសាងសង់ ជាពិសេស អចលនទ្រព្យ នៅតែបន្ត។ ស្ថានភាពនេះ បានបន្តរហូតដល់វិបត្តិកូវីដ ដែលបានបញ្ឈប់ទេសចរណ៍ចិនទាំងស្រុង និងធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ។ វិបត្តិនេះបាននាំឱ្យមានការបោះបង់ចោលអគាររាប់រយខ្នង និងការផ្អាកការដ្ឋានសំណង់។ ទីក្រុងនេះត្រូវបានលម្អដោយកម្មេចកម្មីបែបសហសម័យ។

លោក អ៊ួង សំអាង កត់ត្រាអំពីស្ថានភាពនេះ និងបង្កើតភាពផ្ទុយគ្នាជាមួយនឹងភាពស្ងប់ស្ងាត់ និងសោភ័ណភាពនៃមាត់សមុទ្រ ដោយមិនសង្កត់ធ្ងន់ ដោយមិនទទូចខ្លាំង ដោយមិនប្រកាន់ជំហរ។ គាត់ថតចាប់យកភាពផ្ទុយគ្នានេះ រវាងឆ្នេរ និងអគារខ្ពស់ៗ។ អគារមួយចំនួន ដែលនៅតែបន្តសាងសង់ ត្រូវបានបង្ហាញយ៉ាងស្រទន់នៅក្នុងការរួបរួមដ៏អស្ចារ្យនៃពន្លឺ និងពណ៌។ ការងារមួយ ដែលនឹងតែបន្ត។

លោក Christian Caujolle





© អ៊ួង សំអាង, *The Beloved Kampong som*
*(កំពង់សោមជាទីស្រលាញ់)*

## *15 x 4*

ការតាំងពិព័រណ៍នេះ ដែលជាផ្នែកទីពីរនៃរដូវកាលវប្បធម៌ "តាមទាន់" នៅវិទ្យាស្ថានបារាំងនៃកម្ពុជា នឹងផ្តល់ជូននូវការទស្សនាមើលថយក្រោយរំលឹកឡើងវិញនូវរូបថតប្លែកៗ ដែលបង្ហាញពីការវិវត្ត និងប្រវត្តិនៃមហោស្រពរូបថតភ្នំពេញ។

នៅក្នុងភាពចម្រុះនៃសោភ័ណភាព និងចំណុចកណ្តាលនៃចំណាប់អារម្មណ៍របស់ពួកគេ ពីឯកសាររហូតដល់ការចេញជាគំនិត ពីកំណាព្យបំផុតដល់ការពិពណ៌នាលម្អិតបំផុត ពីការសាងសង់បំផុតរហូតដល់វិចារណញ្ញាណបំផុត អ្នកថតរូបទាំងនេះ បង្កើតវិធីសាស្ត្រដ៏សំខាន់មួយចំពោះការអនុវត្ត និងបញ្ហានានានៃការថតរូបនាពេលបច្ចុប្បន្ននេះ។ ការលុកលុយពិភពលោក នៅតែបន្តរក្សាអត្តន័យរបស់វា នៅពេលដែលការបោះទីតាំងនៅក្នុងវិស័យសិល្បៈសហសម័យ ក៏នៅតែអភិវឌ្ឍផងដែរ។

សំណើរូបថតចំនួន៦០ ដែលស្មោះត្រង់ភ្ជាប់ទៅនឹងមហោស្រពមួយ នឹងស្វាគមន៍ទទួល ចាប់តាំងពីការចាប់ផ្តើមរបស់វា និន្នាការទាំងអស់នៃវិស័



© Manit SRIWANICHPOOM





© Maika Elan, *It felt safe here*, 2016
© Hicham Benohoud, 2020

យថតរូប នឹងរៀបរាប់នៅថ្ងៃនេះ អំពីអារម្មណ៍នានា និងកង្វល់ទាំងឡាយ ដែលរូបថតបានផ្តល់ឱ្យ និងដាស់ឱ្យមានឡើង។ ប្រសិនបើ ដូចដែលយើងធ្លាប់ដឹង ការចងចាំ ប្រវត្តិសាស្ត្រ អត្តសញ្ញាណ ការព្រួយបារម្ភចំពោះធម្មជាតិ និងបរិស្ថាន នៅមានវត្តមាន នោះឥឡូវនេះ យើងអាចមើលឃើញវីដេអូ និងរូបភាពដែលមានចលនា ដែលអវត្តមានទាំងស្រុងក្នុងកំឡុងឆ្នាំដំបូងៗ។

សិល្បករដែលមានវត្តមាននៅក្នុងការតាំងពិពណ៌នេះ សុទ្ធតែបានបន្សល់ទុកនូវសញ្ញាណដ៏សំខាន់មួយក្នុងអំឡុងមហោស្រពមុនៗ។ ដោយមានដើមកំណើតមកពីកន្លែងផ្សេងៗគ្នា ពួកគេបង្ហាញពីការពិតថា សិល្បៈឆ្លងហួសពីព្រំដែនភូមិសាស្ត្រ។ ការតាំងពិព័រណ៍នេះបង្ហាញថា ការច្នៃប្រឌិតសិល្បៈមិនមានដែនកំណត់ទេ ហើយថាការច្នៃប្រឌិតសិល្បៈនេះអាចរីកចម្រើនហួសព្រំដែន និងបង្រួបបង្រួមវប្បធម៌នៅទូទាំងពិភពលោក។

ឈ្មោះរបស់សិល្បករដ៏អស្ចារ្យទាំងនេះ និងប្រទេសកំណើតរបស់ពួកគេ ត្រូវបានរៀបរាប់លម្អិតនៅក្នុងទំព័រខាងក្រោម។

| អាល្លឺម៉ង់ | បែលហ្ស៊ិក | កម្ពុជា | ចិន | កូរ៉េខាងត្បូង | អេស្ប៉ាញ | រុស្ស៊ី | សហរដ្ឋអាមេរិក |
|---|---|---|---|---|---|---|---|
| Leitolf Eva | Vink John | Hann Enong | Li Wei | Ahn Jun | Muñoz Isabel | Gronsky Alexander | Ackerman Michael |
| | | Khiev Kanel | Luo Dan | Jung Yeondoo | | | |
| | | Khun Vannak | | Lee Gapchul | | | |
| | | Khvay Samnang | | Lee Myoung Ho | | | |
| | | Kim Hak | | | | | |
| | | Lim Sokchanlina | | | | | |
| | | Mak Remissa | | | | | |
| | | Mech Sereyrath | | | | | |
| | | Neak Sophal | | | | | |
| | | Soun Sayon | | | | | |
| | | Sovan Philong | | | | | |
| | | Ti Tit | | | | | |
| | | Kong Vollak | | | | | |

© Kvay Samnang



| ហ្វាំងឡង់ | បារាំង | ហូឡង់ | ឡាវ | មីយ៉ាន់ម៉ា | ស្លូវ៉ាគី | ស៊ុយអែត | ស្វីស |
|---|---|---|---|---|---|---|---|
| Brotherus Elina | Briend Clément | Van Empel Ruud | Xiong Ka | Nge Lay | Kollar Martin | Klich Kent | Bernard-Reymond Mathieu |
| | Careme Ludovic | | | | | | Brugmann Matthias |
| | Culmann Olivier | | | | | | Gafsou Mathieu |
| | Dallaporta Raphaël | | | | | | Scheidegger Anna-Katharina |
| | Darzacq Denis | | | | | | Vionnet Corinne |
| | Flore | | | | | | |
| | Freger Charles | | | | | | |
| | Jr | | | | | | |
| | Leblanc Laurence | | | | | | |
| | Lhuisset Emeric | | | | | | |
| | Pernot Mathieu | | | | | | |
| | Rousse Georges | | | | | | |
| | Smith | | | | | | |

| បង់ក្លាដែស | ចក្រភព អង់គ្លេស | ឥណ្ឌា | ម៉ារ៉ុក | សិង្ហបុរី | តៃវ៉ាន់ | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|
| Munem Wassif | Wilson Matt | Chowdury Rasel | Benohoud Hicham | Lee Sean | Chen POL-I | Kiatsirikajorn Lek | Elan Maika |
|  |  | Hura Sohrab |  |  |  | Ruangkritya Miti |  |
|  |  |  |  |  |  | Srikao Harit |  |
|  |  |  |  |  |  | Sriwanichpoom Manit |  |

## *ផ្ទះរូបថត - ស្ទូឌីយោ អ៊ីមេចស៍*

ជាកន្លែងបណ្តុះបណ្តាលថតរូបទីមួយនៅប្រទេសកម្ពុជា ស្ទូឌីយោ អ៊ីមេចស៍ គឺជាសាលាបង្រៀនថតរូប និងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងទីក្រុងភ្នំពេញ ស្ថិតនៅក្រោមការឧបត្ថម្ភរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ស្ទូឌីយោ អ៊ីមេចស៍ ផ្តល់កម្មវិធីសិក្សារយៈពេលពីរឆ្នាំ ដើម្បីអភិវឌ្ឍចំណេះដឹងដ៏រឹងមាំផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងក្នុងវិស័យសិល្បៈ និងបច្ចេកទេសនៃការថតរូប។

សាលាអនុញ្ញាតឱ្យសិស្សរបស់ខ្លួនទទួលបានអត្ថប្រយោជន៍ពីមន្ទីរពិសោធន៍ឌីជីថលមួយ ពីស្ទូឌីយោមួយ ពីកន្លែងតាំងពិព័រណ៍មួយ ពីបណ្ណាល័យមួយសម្បូរបែបដែលមានស្នាដៃជាង២០០០ និងពីមន្ទីរពិសោធន៍ថតរូបអាណាឡូកមួយ។

© ស្ទូឌីយោ អ៊ីមេចស៍ - ផ្ទះរូបថត


IGOR
76

ស្ទូឌីយោ អ៊ីមេចស៍ ក៏នឹងផ្តល់កម្មវិធីអាហារូបករណ៍រយៈពេលពីរឆ្នាំ ដល់សិស្សនិស្សិតដែលចាប់អារម្មណ៍ចូលប្រឡូកវិស័យថតរូបផងដែរ។

ស្ទូឌីយោ អ៊ីមេចស៍ ត្រៀមរៀបចំយុវជនកម្ពុជាជំនាន់ក្រោយ សម្រាប់អាជីពផ្សេងៗគ្នាដូចជា អ្នកថតរូបសិល្បៈ អ្នកថតរូបស្ទូឌីយោ/ពាណិជ្ជកម្ម អ្នកថតរូបព្រឹត្តិការណ៍ អ្នកថតវីដេអូ អ្នកថតរូបកាសែត អ្នកកែសម្រួលរូបភាព និងក្រោយផលិតកម្ម នាយកពិព័រណ៍ និងអ្នកបោះពុម្ព។

វគ្គសិក្សានេះ ផ្តល់នូវមេរៀនសំខាន់ៗមួយចំនួនដូចជា ការបណ្តុះបណ្តាលបច្ចេកទេសមួយរឹងមាំ បទពិសោធន៍ជាក់ស្តែង ការបណ្តុះបណ្តាលទ្រឹស្តី និងអំពីប្រវត្តិនៃការថតរូប សិក្ខាសាលា និងជំនួបជាទៀងទាត់ជាមួយអ្នកជំនាញ និងសូម្បីតែវគ្គសិក្សាជាភាសាបរទេស។ នៅពេលបញ្ចប់វគ្គបណ្តុះបណ្តាល និស្សិតនឹងទទួលបានសញ្ញាប័ត្រ បញ្ជាក់សុពលភាពសិក្សារយៈពេលពីរឆ្នាំរបស់ពួកគេ។

សាលាក៏ផ្តល់ជូននូវសិក្ខាសាលាសម្រាប់អ្នកស្រលាញ់ចូលចិត្តការថតរូប និងអ្នកថតរូបកម្រិតខ្ពស់ ដែលអាចឱ្យមនុស្សគ្រប់គ្នាពង្រឹងសមត្ថភាពរបស់ពួកគេ។

ក្រុមគ្រូបង្រៀន និងអ្នកដឹកនាំ ត្រូវបានផ្តុំឡើងដោយអ្នកជំនាញផ្នែកថតរូប និងសិល្បករដែលទទួលបានការទទួលស្គាល់ ដោយធានាបាននូវការបង្រៀនមួយដែលមានគុណភាពខ្ពស់ ដើម្បីត្រៀមរៀបចំសិស្សនិស្សិតឱ្យទទួលបានជោគជ័យក្នុងវិស័យថតរូប។

# ព័ត៌មានមានផ្សេងៗ

ផ្ទះលេខ ២១៨ ផ្លូវ ១៨៤ – BP ៨២៧
+៨៥៥ (០)២៣ ៩៨៥ ៦១១ / ៦១២
**info@ifcambodge.com**

## ម៉ោងធ្វើការ៖

### វិចិត្រសាលរបស់ វិទ្យាស្ថានបារាំងកម្ពុជាបើក៖

→ ពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ ៖ ពីម៉ោង ១០ ព្រឹក ដល់ម៉ោង ៦ ល្ងាច

→ ពីថ្ងៃសុក្រ ដល់ថ្ងៃសៅរ៍៖ ពីម៉ោង ១០ ព្រឹកដល់ម៉ោង ៥ ល្ងាច

វិទ្យាស្ថានបារាំងផ្តល់ជូននូវការទស្សនាពិព័រណ៍ អមដោយអ្នកសម្រប សម្រួលណែនាំពន្យល់ ដោយឥតគិតថ្លៃ នៅវិទ្យាស្ថានបារាំងនៅកម្ពុជា ។

**កក់ទុកជាមុនតាម៖**

info@ifcambodge.com

# ទស្សនកិច្ច និងសិក្ខាសាលា

## សម្រាប់សាធារណៈជនទូទៅ

**ការទស្សនាពិព័រណ៍អមដោយអ្នកសម្របសម្រួលណែនាំពន្យល់**

ជាភាសាបារាំង ខ្មែរ និងអង់គ្លេស

→ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ , ពីម៉ោង ៩ព្រឹក ដល់ម៉ោង ៥ល្ងាច

## សាលារៀន និងអង្គការក្រៅរដ្ឋាភិបាល

**ទស្សនកិច្ចរៀបចំសម្រាប់គ្រូបង្រៀន**

ជាភាសាបារាំង ខ្មែរ ឬ អង់គ្លេស

→ កក់ទុកជាមុន - ឥតគិតថ្លៃ

**ទស្សកិច្ចអមដោយអ្នកសម្របសម្រួលពន្យល់ សម្រាប់ថ្នាក់រៀន**

ជាភាសាបារាំង ខ្មែរ ឬអង់គ្លេស

→ ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍៖ ម៉ោង ៩:00 ព្រឹក - ១២:00 ពីម៉ោង២:00 រសៀល - ដល់ម៉ោង ៥:00 រសៀល ។

→ កក់ទុកជាមុន - ឥតគិតថ្លៃ

**ការបញ្ចាំងភាពយន្ត**

២ ដុល្លារក្នុងម្នាក់

## ក្រុមសម្របសម្រួលវប្បធម៌កំពុងរង់ចាំលោកអ្នកនៅវិទ្យាស្ថានបារាំងកម្ពុជា!

**អ្នកគ្រប់គ្រងវប្បធម៌៖**
លោក កោ បូរិន

**ប្រធានផ្នែកសម្របសម្រួល និងភាពយន្ត៖**
លោក ថេន វ៉ូឈីវែន

**ទទួលខុសត្រូវចំពោះការសម្រុះសម្រួលវប្បធម៌៖**
Chloé LAVENANT


## ទំនាក់ទំនង៖

info@ifcambodge.com
ទូរស័ព្ទ: +855 (0)23 985 611 / 612